រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៤៦៦៣ ប្រក.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
# ស្តីពី
# ការកំណត់គោលដៅឃុំឃាំងជនជាប់ឃុំ
# សម្រាប់មណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល មាត្រា៩ មាត្រា១០ មាត្រា៤២ និងមាត្រា៤៥ នៃអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញប្រកាសលេខ ៩៨៨ ប្រក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ។

## សម្រេច

**ប្រការ ១._**

ប្រកាសនេះ កំណត់អំពីការបែងចែកគោលដៅឃុំឃាំងជនជាប់ឃុំ ក្នុងគោលបំណងធានាប្រសិទ្ធភាព ក្នុងការអនុវត្តមុខងាររបស់មណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត ឱ្យស្របទៅតាមស្ថានភាព ជនជាប់ឃុំ និងស្ថានភាពពន្ធនាគារ។

**ប្រការ ២._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

**ប្រការ ៣._**

មណ្ឌលអប់រំកែប្រែ មានមុខងារគ្រប់គ្រងជនជាប់ឃុំជាទណ្ឌិត ក្នុងគោលដៅអនុវត្តកម្មវិធីអប់រំកែប្រែ បណ្តុះបណ្តាលវិជ្ជាជីវៈ ស្តារនីតិសម្បទា និងកម្មវិធីសមាហរណកម្ម។

មណ្ឌលអប់រំកែប្រែមានចំនួន០៤ រួមមាន មណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី២ មណ្ឌល អប់រំកែប្រែទី៣ និងមណ្ឌលអប់រំកែប្រែទី៤ ត្រូវកំណត់គោលដៅគ្រប់គ្រងការឃុំឃាំងជនជាប់ឃុំដូចខាង ក្រោម៖

- **មណ្ឌលអប់រំកែប្រែទី១** មានទីតាំងនៅក្នុងរាជធានីភ្នំពេញ ទទួលអនុវត្តឃុំឃាំងជនជាប់ឃុំ បុរសជាទណ្ឌិត ដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ចាប់ពី៥ឆ្នាំ រហូតដល់ ក្រោម ១៥ឆ្នាំ។
- **មណ្ឌលអប់រំកែប្រែទី២** មានទីតាំងនៅក្នុងរាជធានីភ្នំពេញ ទទួលអនុវត្តឃុំឃាំងជនជាប់ឃុំ ស្ត្រីជាទណ្ឌិត។
- **មណ្ឌលអប់រំកែប្រែទី៣** មានទីតាំងនៅក្នុងខេត្តត្បូងឃ្មុំ ទទួលអនុវត្តឃុំឃាំងជនជាប់ឃុំ បុរសជាទណ្ឌិត ដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ចាប់ពី១៥ឆ្នាំ រហូតដល់ មួយជីវិត។
- **មណ្ឌលអប់រំកែប្រែទី៤** មានទីតាំងនៅក្នុងខេត្តពោធិ៍សាត់ ទទួលអនុវត្តឃុំឃាំងជនជាប់ឃុំ បុរសជាទណ្ឌិត ដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារក្រោម៥ឆ្នាំ ឬអនុវត្តទោស ពន្ធនាគារនៅសល់ក្រោម៥ឆ្នាំ។

**ប្រការ ៤._**

ពន្ធនាគាររាជធានី ខេត្ត មានមុខងារគ្រប់គ្រងជនជាប់ឃុំកំពុងស្ថិតក្នុងដំណើរការនីតិវិធីតុលាការ និងអាចរក្សាទុកជនជាប់ឃុំជាទណ្ឌិតដែលស្ថិតក្នុងចំណាត់ថ្នាក់សន្តិសុខទាប បានត្រឹមចន្លោះពី១០% ទៅ១៥% នៃចំនួនទណ្ឌិតសរុបជាក់ស្តែង សម្រាប់ទុកបម្រើសេវានានាក្នុងពន្ធនាគារ។

**ប្រការ ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦._**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ១៥កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ១០ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ